# សេចក្តីប្រកាស អ៉ី-សាក់កាអ៊ូ

(E-SAK KA OU DECLARATION)

សេចក្តីប្រកាសនេះធ្វើឡើងនៅឯសន្និសីទថ្នាក់តំបន់អាស៊ីស្តីពីសិទ្ធិជនជាតិដើមភាគតិច ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ ដែលប្រារព្ធធ្វើនៅថ្ងៃទី ៥-៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខេត្តក្រាប៊ី ប្រទេសថៃ

## ជីវិត និងដីធ្លី



*គឺតែមួយៗ យើងដូចគ្នានឹងដីធ្លីៗ*
*យើងកើតមកពីដីៗ យើងត្រឡប់ទៅកាន់ដីវិញ ”*

*“ យើងមិនអាចមើលឃើញដីនោះជាកម្មសិទ្ធិរបស់យើងទេ*
*ព្រោះយើងទៅវិញទេដែលជាកម្មសិទ្ធិរបស់ដីៗ*

*“ បើយើងយល់ពីចំណុចនេះយើងនឹងដឹងពីរបៀបចែករំលែក*
*និងផ្តល់ឲ្យៗប៉ុន្តែបើយើងមិនយល់យើងនឹងឈ្លោះគ្នា*
*និងដណ្តើមយកដីធ្វើជាកម្មសិទ្ធិ*
*របស់យើង ”*

-ចូនី អូដូចៅ ( Joni Odochao ) ចាស់ទុំជនជាតិការ៉ែន

# សេចក្ដីប្រកាស អ៊ី-សាក់កាអ៊ូ

(E-SAK KA OU DECLARATION)

សេចក្ដីប្រកាសនេះធ្វើឡើងនៅឯសន្និសីទថ្នាក់តំបន់អាស៊ីស្ដីពីសិទ្ធិជនជាតិដើមភាគតិច ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ ដែលប្រារព្ធធ្វើនៅថ្ងៃទី ៥-៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខេត្តក្រាប៊ី ប្រទេសថៃ

**“ ជីវិតនិងដីធ្លីគឺតែមួយ។ យើងដូចគ្នានឹងដីធ្លី។ យើងកើតមកពីដី។ យើងត្រឡប់ទៅកាន់ដីវិញ។**

**“ យើងមិនអាចមើលឃើញដីនោះជាកម្មសិទ្ធិរបស់យើងទេព្រោះ យើងទៅវិញទេដែលជាកម្មសិទ្ធិរបស់ដី។**

**“ បើយើងយល់ពីចំណុចនេះយើងនឹងដឹងពីរបៀបចែករំលែកនិងផ្ដល់ឲ្យ។ ប៉ុន្តែបើយើងមិនយល់យើងនឹងឈ្លោះគ្នា និងដណ្ដើមយកដីធ្វើជាកម្មសិទ្ធិរបស់យើង”**

**– ចូនី អូដូចៅ (Joni Odochao) ចាស់ទុំជនជាតិការ៉ែន**

ទ្វីបអាស៊ីគឺជាតំបន់មានភាពសម្បូរបែបនៃជីវចម្រុះនិងវប្បធម៌ចម្រុះដែលពួកយើងជាជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្សនិងគ្រប់គ្រងដីធ្លី ដែនដី ទឹកនិងធនធានរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ យើងក៏ប្រឈមមុខនឹងបញ្ហាប្រឈមនិងការគំរាមកំហែងជាច្រើនពីការប្រែប្រួលអាកាសធាតុ ការកាប់បំផ្លាញព្រៃឈើ ការរិចរិលដីធ្លី ការរំលោភសិទ្ធិមនុស្ស និង ការអភិវឌ្ឍ។ ដូច្នេះ វាចាំបាច់សម្រាប់រដ្ឋាភិបាលក្នុងការគាំទ្រ ទទួលស្គាល់ និងគោរពគុណតម្លៃ ការប្រតិបត្តិ ដីធ្លី ដែនដី ទឹក និងធនធានរបស់យើង។

ដោយមានការបង្ហាញផ្លូវ ដោយឧត្តមគតិរបស់បុព្វបុរស និងព្រឹទ្ធាចារ្យរបស់យើងដែលបានការពារដីធ្លី ដែនដី ទឹក និងធនធានរបស់យើងតាំងពីយូរលង់ណាស់មកហើយ។

ដោយមានការប្ដេជ្ញាចិត្តក្នុងការ បំពេញតួនាទីរបស់យើងជាអ្នកមើលការខុសត្រូវលើដីធ្លី ដែនដី ទឹក ធម្មជាតិ និងបេតិកភណ្ឌវប្បធម៌របស់យើង។

ដោយមានការជំរុញទឹកចិត្ត ដោយបំណងប្រាថ្នាដើម្បីបន្តលើកកម្ពស់តម្លៃសាមគ្គីភាពសហគមន៍ជនជាតិដើមភាគតិច ការយកចិត្តទុកដាក់ និងការចែករំលែកទៅកាន់មនុស្សជំនាន់ក្រោយនិងដល់សហគមន៍កាន់តែទូលំទូលាយ។

ដោយមានការព្រួយបារម្ភ ចំពោះការបាត់បង់ជីវចម្រុះយ៉ាងឆាប់រហ័ស ការឡើងកំដៅផែនដីដែលមិនអាចគ្រប់គ្រងបាន និងការរីករាលដាលនៃការបំពុលបរិស្ថានដែលទាំងអស់នេះកំពុងធ្វើឱ្យខូចគុណភាពជីវិតរបស់យើង និងគំរាមកំហែងដល់វប្បធម៌របស់យើង ដោយមើលឃើញយ៉ាងច្បាស់ពីអនាគតដ៏គួរឱ្យសង្វេគសម្រាប់មនុស្សនាពេលបច្ចុប្បន្ននិងអនាគតព្រមទាំងភពផែនដីនិងជីវិតនៅលើផែនដី។

*E-sak Ka Ou Declaration*

"E-sak Ka Ou" is a term used by the Urak Lawoi Indigenous Peoples to refer to the place where their ancestors first settled on Lanta Island, Krabi Province, Thailand. It means the gill of the Manta ray.

ដោយដឹងថា វិបត្តិជីវចម្រុះ អាកាសធាតុ និងការបំពុលត្រូវបានចាក់ឫសនៅក្នុងរចនាសម្ព័ន្ធ និងទំនាក់ទំនងនៃសេដ្ឋកិច្ចសង្គមនិងនយោបាយដោយអយុត្តិធម៌ ដែលរំលោភលើសិទ្ធិមនុស្សនិងជនជាតិដើមភាគតិច ដែលជនល្មើស និងអ្នកមានដែនសមត្ថកិច្ចគួរតែទទួលខុសត្រូវ។

ដោយបញ្ជាក់ ជាថ្មីថាយើងមានសិទ្ធិទទួលបានសិទ្ធិសមូហភាពរបស់យើងដូចមានចែងនៅក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ដែលរដ្ឋាភិបាលទាំងអស់ត្រូវតែទទួលស្គាល់និងគោរពនៅក្នុងក្របខ័ណ្ឌច្បាប់និងគោលនយោបាយរបស់ពួកគេ។ ការប៉ុនប៉ងរបស់រដ្ឋាភិបាលក្នុងការបង្រួញសិទ្ធិជនជាតិដើមភាគតិចតាមរយៈការធ្វើទូទៅនីយកម្ម និងការប្រើប្រាស់ពាក្យពេជន៍ផ្សេងទៀតដែលបំភ្លៃខុសពីអត្តសញ្ញាណ និងសិទ្ធិស្របច្បាប់របស់យើងមិនត្រូវអត់ឱនឡើយ។

ដោយ អះអាងថាការចូលរួមយ៉ាងសកម្មរបស់ជនជាតិដើមភាគតិចនៅក្នុងដំណើរការរៀបចំគោលនយោបាយនិងការសម្រេចចិត្តពាក់ព័ន្ធទាំងអស់គឺមានសារៈសំខាន់សម្រាប់ការសម្រេចបាននូវចក្ខុវិស័យនិងគោលដៅនៃការរស់នៅរួមគ្នានិងសុខុមាលភាពរបស់មនុស្សនិងធម្មជាតិ។

យើងជាគណៈប្រតិភូចំនួន៤៧នាក់ចូលរួមសន្និសីទថ្នាក់តំបន់អាស៊ីស្តីពីសិទ្ធិជនជាតិដើមភាគតិច ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ ដែលប្រារព្ធឡើងនៅថ្ងៃទី៥-៨ ខែវិច្ឆិកា ឆ្នាំ ២០២៣ នៅខេត្តក្រាប៊ី(Krabi)ប្រទេសថៃដែលតំណាងឱ្យសហគមន៍ជនជាតិដើមភាគតិចចំនួន៣២សហគមន៍ ស្ត្រី យុវជន ជនមានពិការភាព និងអង្គការអភិវឌ្ឍន៍មកពីប្រទេសចំនួន១១ បានបញ្ចប់សន្និសីទជាមួយនឹងការអះអាងអំពីសិទ្ធិរបស់យើងនិងការអំពាវនាវឱ្យមានការការពារដើម្បីធានាបាននូវសិទ្ធិទាំងនេះដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច(UNDRIP)។

ឥឡូវនេះយើងសូមដាក់ចេញសេចក្តីប្រកាសសន្និសីទ នេះជាសេចក្តីថ្លែងការណ៍នៃជំហររួមរបស់យើងជាជនជាតិដើមភាគតិចឆ្ពោះទៅរកដំណោះស្រាយរួមគ្នាចំពោះកង្វល់និងបញ្ហាបន្ទាន់ដែលយើង និងមនុស្សជាតិទាំងមូលកំពុងប្រឈមមុខ។

## សារៈសំខាន់និងភាពបន្ទាន់នៃការប្តេជ្ញាចិត្តជាសាកល និងអភិក្រមនៃសង្គមទាំងមូល

ភាពបន្ទាន់ក្នុងការដោះស្រាយវិបត្តិជីវចម្រុះ និងអាកាសធាតុគឺបង្ហាញឱ្យឃើញយ៉ាងច្បាស់ និងបានដឹងពីផលរបស់វាមកលើជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងសហគមន៍របស់យើង ដែលកំពុងបង្កផលប៉ះពាល់មកលើវប្បធម៌ ជីវិតរស់នៅ និងចំណេះដឹងជនជាតិដើមភាគតិចរបស់យើងនៅគ្រប់ស្ថានប្រព័ន្ធ និងតំបន់ទាំងអស់នៃពិភពលោក។ បម្រែបម្រួលអាកាសធាតុនិងការបាត់បង់ជីវចម្រុះគឺជាបញ្ហាស្លាប់រស់សម្រាប់ពួកយើងទាំងអស់គ្នា ហើយសិទ្ធិមនុស្សរបស់យើងក្នុងការរស់នៅ និងសិទ្ធិទទួលបានបរិស្ថានស្អាត ផាសុខភាព និងនិរន្តរភាពគឺកំពុងប្រឈមនឹងហានិភ័យ។ ភាពបន្ទាន់នេះក៏ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយដំណើរការនានារបស់អង្គការសហប្រជាជាតិរួមមានអនុសញ្ញាស្តីពីជីវៈចម្រុះ( CBD )និងអនុសញ្ញាក្របខ័ណ្ឌស្តីពីការប្រែប្រួលអាកាសធាតុ( UNFCCC )។ ដំណើរការទាំងនេះអំពាវនាវឱ្យមានការផ្លាស់ប្តូរដោយរំលេចឱ្យឃើញថាដំណោះស្រាយដូចមាននាពេលបច្ចុប្បន្ននេះមិនមែនជាជម្រើសទៀតទេ។ ពួកគេក៏អំពាវនាវឲ្យមានអភិក្រមរបស់រដ្ឋាភិបាលនិងសង្គមទាំងមូលដែលជារឿងបន្ទាន់បំផុតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

យើងទទួលស្គាល់ និងស្វាគមន៍ថាការរួមចំណែក សិទ្ធិ ចំណេះដឹង និងគុណតម្លៃរបស់យើងត្រូវបានទទួលស្គាល់និងគោរពកាន់តែខ្លាំងឡើងនៅក្នុងដំណើរការសកល ប៉ុន្តែយើងមានការព្រួយបារម្ភយ៉ាងខ្លាំងដែលវាមិនត្រូវបានរំលេចឡើងនៅក្នុងដំណើរការជាតិ ច្បាប់ និងក្របខ័ណ្ឌគោលនយោបាយ។ នៅក្នុងប្រទេសជាច្រើនច្បាប់ជាតិគឺផ្ទុយនឹងច្បាប់និងបទដ្ឋានអន្តរជាតិដូចជា UNDRIPអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី( CEDAW )អនុសាសន៍ទូទៅលេខ៣៩ ក្របខ័ណ្ឌជីវៈចម្រុះសាកលក្រុងម៉ុងរេអាល់-គុនមីងស្តីពីអនុសញ្ញាជីវៈចម្រុះ (KMGBF) និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។

## ការចូលរួមនៅក្នុងយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិជីវចម្រុះ( NBSAPs ) និងការរួមចំណែកនៅថ្នាក់ជាតិ( NDCs )

ដើម្បីដំណើរការអភិក្រមនៃសង្គមទាំងមូល យើងអំពាវនាវឱ្យរដ្ឋាភិបាលធានាឱ្យមានការចូលរួមយ៉ាងពេញលេញនិងមានប្រសិទ្ធភាពរបស់ជនជាតិដើមរួមទាំងស្ត្រី យុវជននិងជនមានពិការជនជាតិដើមភាគតិច ក្នុងការសម្រេចចិត្តទាក់ទងនឹងជីវចម្រុះនិងការប្រែប្រួលអាកាសធាតុ។ ដំណើរការនេះពិតជាមានសារៈសំខាន់ជាពិសេសក្នុងការអភិវឌ្ឍ ឬការពិនិត្យឡើងវិញនិងការធ្វើបច្ចុប្បន្នភាពនៃយុទ្ធសាស្ត្រនិងផែនការសកម្មភាពជីវចម្រុះជាតិ( NBSAPs ) ដើម្បីបន្សុីគ្នាជាមួយក្របខណ្ឌជីវៈចម្រុះសកល Kunming-Montreal( KMGBF )និងការរួមចំណែកដែលបានកំណត់ដោយនៅកម្រិតថ្នាក់ជាតិ( NDCs )តាមរយៈការបង្កើតឱកាសសម្រាប់ជនជាតិដើមភាគតិចបានចូលរួម។ យន្តការចូលរួមប្រកបដោយប្រសិទ្ធភាពនៅគ្រប់ដំណាក់កាលនៃដំណើរការទាំងនេះត្រូវតែបង្កើតឡើងជាបន្ទាន់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឬពង្រឹងនៅកន្លែងដែលមានស្រាប់។

NBSAPs និងNDCs មិនគួរត្រូវបានផ្តោតតែលើការអភិរក្សពីថ្នាក់លើចុះក្រោម សកម្មភាពការកាត់បន្ថយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនោះឡើយដោយមិនមានការយល់ព្រមដោយសេរី និងផ្តល់ព័ត៌មានជាមុន(FPIC) ដែលសកម្មភាពទាំងនេះកំពុងប៉ះពាល់ដល់យើងនិងរំលោភសិទ្ធិរបស់យើងរួចហើយ។ NBSAPs និង NDCs គួរតែផ្អែកលើវិធីសាស្រ្តផ្អែកលើសិទ្ធិមនុស្សរួមទាំងគោលដៅដ៏រឹងមាំមួយដើម្បីធានាសិទ្ធិកាន់កាប់រួមរបស់យើង និងដើម្បីធានាបាននូវការយល់ព្រមដោយសេរីនិងជូនព័ត៌មានជាមុន(FPIC)សម្រាប់សកម្មភាពជីវចម្រុះនិងអាកាសធាតុទាំងអស់នៅលើដីធ្លី ដែនដីដែន ទឹក និងធនធានរបស់យើង។ ពួកគេក៏ត្រូវតែទទួលស្គាល់ ការរួមចំណែក គុណតម្លៃ ការប្រតិបត្តិនិងទស្សនៈរបស់យើងលើការអភិរក្សការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការស្តារឡើងវិញនូវធម្មជាតិនិងការកាត់បន្ថយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## គុណតម្លៃនៃចំណេះដឹងជនជាតិដើមភាគតិចក្នុងការប្រែប្រួលអាកាសធាតុនិងការអភិរក្សជីវចម្រុះ

ចំណេះដឹងរបស់យើងមានលក្ខណៈរួម និងមើលឃើញពីទំនាក់ទំនងគ្នាទៅវិញទៅមកនៃពិភពលោកដែលយើងរស់នៅ។ វាគឺជាផែនទីវប្បធម៌និងអេកូឡូស៊ីនៃទឹកដីរបស់យើង។ វាគឺជាមូលដ្ឋាននៃសុខុមាលភាពនិងភាពធន់នៃវប្បធម៌របស់សហគមន៍យើង ហើយវារក្សាបាននូវទំនាក់ទំនងល្អជាមួយនឹងពិភពអរូបីដូចដែលបានស្តែងឱ្យឃើញក្នុងដួងព្រលឹងរបស់យើងក៏ដូចជាជាមួយនឹងប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានប្រកបដោយផាសុខភាព។ បន្តពីមួយជំនាន់ទៅមួយជំនាន់ ការបណ្តុះស្មារតី និងការផ្ទេរចំណេះដឹងរបស់យើង គឺមានសារៈសំខាន់សម្រាប់សុខុមាលភាព និងការស្តារឡើងវិញនូវតុល្យភាពអេកូឡូស៊ី និងបរិស្ថាន និងជីវិតនៅលើភពផែនដី។ ចំណេះដឹងរបស់យើងស្ថិតនៅជារួមជាមួយចាស់ទុំ ស្ត្រី យុវជន និងកុមារដែលប្រើប្រាស់ជាប្រយោជន៍រួមនៃសហគមន៍ និងមានភាពសមធម៌គ្រប់ពហុវិស័យ។ ទោះជាយ៉ាងណាក៏ដោយចំណេះដឹងរបស់យើងកំពុងធ្លាក់ចុះដោយសារតែកត្តាខាងក្រៅដូចជាការបំផ្លិចបំផ្លាញនៃប្រព័ន្ធអប់រំរបស់យើង និងការទម្លាក់តម្លៃនិងការបំផ្លាញនៃវប្បធម៌និងទស្សនៈគតិរបស់យើង។

យើងអំពាវនាវដល់អ្នកទទួលកាតព្វកិច្ចនិងសហគមន៍ពិភពលោកឱ្យទទួលស្គាល់លក្ខណៈរួមនៃប្រព័ន្ធចំណេះដឹងរបស់យើង និងតួនាទីសំខាន់នៃប្រព័ន្ធទាំងនេះក្នុងការសម្រេចបាននូវទិសដៅនិងគោលដៅរបស់UNCBDនិងUNFCCC ជាពិសេសនៅក្នុងផែនការសម្របខ្លួនរបស់ជាតិ(NAPs) NBSAP និង NDCs។ យើងនឹងខិតខំប្រឹងប្រែងធ្វើឱ្យចំណេះដឹងនិងការប្រតិបត្តិរបស់យើងរស់ឡើងវិញតាមរយៈការចងក្រង និងការផ្សព្វផ្សាយអំពីការប្រតិបត្តិល្អ និងភស្តុតាងនានានឹងអនុញ្ញាតឱ្យយើងលើកកម្ពស់ប្រព័ន្ធចំណេះដឹងរបស់យើងទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ និងគោលនយោបាយ។ ដើម្បីសម្រេចបាននូវចំណុចនេះធនធានត្រូវតែបែងចែកឱ្យបានគ្រប់គ្រាន់ដល់ជនជាតិដើមភាគតិចដោយមានការផ្តល់មូលនិធិដោយផ្ទាល់ដល់អង្គការ និងសហគមន៍របស់យើង។

## ការទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចក្នុងការអភិរក្ស

គោលដៅទី៣នៃ ក្របខ័ណ្ឌ KMGBF មានគោលបំណងធានាថានៅឆ្នាំ ២០៣០ យ៉ាងហោចណាស់ ៣០% នៃដីធ្លី ដែនដី ទឹក និងតំបន់សមុទ្រត្រូវបានអភិរក្សនិងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពតាមរយៈប្រព័ន្ធនៃតំបន់ការពារនិងវិធានការផ្សេងទៀត ដោយទទួលស្គាល់ដែនដីជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់រដ្ឋនិងក្របខ័ណ្ឌគោលនយោបាយស្ដីពីតំបន់ការពារនិងការអភិរក្សបានបន្តនូវកេរដំណែលអាណានិគមនៃវិធីសាស្ត្រអភិរក្សដោយបង្កើតតំបន់ការពារដែលមិនទទួលស្គាល់ការប្រតិបត្តិក្នុងការអភិរក្សរបស់ជនជាតិដើមភាគតិច ឬកម្មសិទ្ធិសមូហភាពរបស់យើងលើដីធ្លីទឹកដី ទឹក និងធនធានជនជាតិដើមភាគតិច។ វិធីសាស្ត្រនេះបំពានបន្ថែមទៀតលើសិទ្ធិរបស់យើង ធ្វើឱ្យសហគមន៍របស់យើងផ្លាស់ទីលំនៅ ការដាក់ទោសទណ្ឌលើអ្នកការពារសិទ្ធិជនជាតិដើមភាគតិច បង្កើតជម្លោះ និងថែមទាំងបរាជ័យក្នុងការសម្រេចឱ្យបានលទ្ធផលវិជ្ជមាននៃការការពារជីវចម្រុះ។

យើងអំពាវនាវឱ្យរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលធ្វើការលើផ្នែកអភិរក្ស និងស្ថាប័នពាក់ព័ន្ធត្រូវធ្វើកំណែទម្រង់ច្បាប់អភិរក្ស និងក្របខ័ណ្ឌគោលនយោបាយរបស់ពួកគេ ហើយពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្ររបស់ពួកគេ ដោយទទួលស្គាល់ដែនដីជនជាតិដើមភាគតិចថាជាទិសដៅទីបីក្រៅពីតំបន់ការពារនិងវិធានការអភិរក្សតាមតំបន់ដែលមានប្រសិទ្ធភាពផ្សេងទៀត( OECMs )នៅក្នុងការសម្រេចបាននូវគោលដៅទី៣។ រដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុ និងអាជីវកម្មត្រូវតែបញ្ចប់ការរើសអើងការដាក់ទោសទណ្ឌ និងឃាតកម្មមកលើជនជាតិដើមភាគតិច ហើយត្រូវធានាថាគ្មានការរំលោភសិទ្ធិមនុស្សក្នុងការអនុវត្តកម្មវិធី គម្រោង និងសកម្មភាពអភិរក្សជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ។ ពួកគេគួរតែគាំទ្រវិធីរបស់ជនជាតិដើមយើងក្នុងការអភិរក្សដែនដីរបស់យើង និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។

## ទីផ្សារកាបូននិងឥណទានជីវចម្រុះ

គម្រោងឬកម្មវិធីឥណទានកាបូននិងជីវចម្រុះណាមួយនៅលើដីធ្លី ដែនដី និងទឹករបស់យើងមិនអាចប្រព្រឹត្តទៅបានទេបើគ្មានការយល់ព្រមដោយ សេរី និងជូនដំណឹងជាមុន ( FPIC )។ យើងទាមទារព័ត៌មានពេញលេញនិងតម្លាភាពអំពីទីផ្សារទាំងនេះ របៀបដែលទីផ្សារទាំងនេះមានទំនាក់ទំនងនិងផលប៉ះពាល់ដល់ស្ថាប័ន និងរចនាសម្ព័ន្ធប្រពៃណីរបស់យើងនិងអ្វីផ្សេងទៀតដែលជាប់ទាក់ទងនឹងសិទ្ធិរបស់យើងចំពោះបូរណភាពដីធ្លី ដែនដី ទឹក ធនធាន និងវប្បធម៌។ ការវាយតម្លៃហេតុផលប៉ះពាល់មកលើវប្បធម៌ បរិស្ថាន និងសិទ្ធិមនុស្សត្រូវតែធ្វើឡើងដោយមានការចូលរួមពេញលេញពីជនជាតិដើមភាគតិច ដើម្បីឱ្យពួកយើងអាចធ្វើការសម្រេចចិត្តជាសមូហភាពនិងអាចចរចាដោយយុត្តិធម៌និងសមធម៌ដើម្បីផលប្រយោជន៍រួម។

MALEYA Foundation

PEREMPUAN AMAN

NEFIN

ទីផ្សារកាបូន និងជីវចម្រុះអាចបង្វែរការយកចិត្តទុកដាក់ឆ្ងាយពីគោលដៅចម្បង ពោលគឺកាត់បន្ថយការបញ្ចេញកាបូនយ៉ាងច្រើនពីអ្នកបំពុល និងតួអង្គផ្សេងទៀតដែលទទួលខុសត្រូវជាប្រវត្តិសាស្ត្រចំពោះការប្រែប្រួលអាកាសធាតុ។គំនិតចំពោះការទូទាត់គ្នាបានមិនមែនជាដំណោះស្រាយពិតប្រាកដទេ ពោលគឺការកាត់បន្ថយប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់(GHGs)ទៅវិញទេ ទើបជាគន្លឹះសំខាន់។ យន្តការនិងស្តង់ដារដែលគ្រប់គ្រងដោយសហគមន៍គឺចាំបាច់ជាជាងការចាប់យកទីផ្សារកាបូននិងជីវចម្រុះ ដែលយកធម្មជាតិធ្វើជាទំនិញ។

## តួនាទីរបស់ជនជាតិដើមភាគតិចក្នុងការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងរាយការណ៍

យើងទាមទារទៅរដ្ឋាភិបាលនិងតួអង្គពាក់ព័ន្ធដើម្បីធានានូវការចូលរួមពេញលេញប្រកបដោយប្រសិទ្ធភាព និងសមភាពរបស់ជនជាតិដើមភាគតិច រួមទាំងស្ត្រីជនជាតិដើមភាគតិច យុវជន និងជនមានពិការភាពក្នុងការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការរាយការណ៍អំពីជីវចម្រុះនិងការប្រែប្រួលអាកាសធាតុរួមទាំងតាមរយៈការរៀបចំទិន្នន័យពង្រាយនៅគ្រប់ដំណាក់កាល។

រដ្ឋាភិបាលត្រូវតែដាក់បញ្ចូលយន្តការគាំទ្រ(ដូចជាជំនួយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ)ក្នុងការរៀបចំផែនការសកម្មភាពទាក់ទងអាកាសធាតុនិងជីវចម្រុះ។ កម្មវិធីនិងមូលនិធិត្រូវតែអនុវត្តដោយមានយន្តការការពារដូចជាគោលការណ៍យល់ព្រមដោយសេរី និងមានការជូនដំណឹងជាមុន(FPIC)ពីជនជាតិដើមភាគតិចស្របតាម UNDRIP។

រដ្ឋាភិបាលក៏ត្រូវតែទទួលស្គាល់និងគាំទ្រ រួមទាំងតាមរយៈការផ្តល់មូលនិធិដោយផ្ទាល់ការរួមចំណែកក្នុងប្រព័ន្ធព័ត៌មាន និងតាមដានផ្អែកលើសហគមន៍(CBMIS)លើជីវចម្រុះនិងការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិត ជាពិសេសនៅកម្រិតមូលដ្ឋាននិងក្នុងរបាយការណ៍ជាតិដោយទទួលស្គាល់ការរួមចំណែកនៃប្រព័ន្ធចំណេះដឹង សូចនាករ និងឧបករណ៍រួមជាមួយនឹងការច្នៃប្រតិដ្ឋបែបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

## ការបាត់បង់និងការខូចខាត

ជនជាតិដើមភាគតិចមានបទពិសោធន៍ជួបប្រទះនឹងការបាត់បង់និងការខូចខាតផ្នែកសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដោយសារតែការប្រែប្រួលអាកាសធាតុខណៈពេលដែលជនជាតិដើមភាគតិចរួមចំណែកតិចតួចដល់ការឡើងកំដៅផែនដីនិងការបាត់បង់ជីចម្រុះ។ រដ្ឋាភិបាលត្រូវតែធានាថាមូលនិធិដោះស្រាយការបាត់បង់និងការខូចខាតនេះត្រូវមានគោលនយោបាយសម្រាប់ជនជាតិដើមភាគតិច ក្រុមប្រឹក្សាយោបល់ជនជាតិដើមភាគតិច និងតំណាងជនជាតិដើមភាគតិចនៅក្នុងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តនៃរចនាសម្ព័ន្ធអភិបាលកិច្ចដែលបានស្នើឡើងនៃមូលនិធិនេះ។ លើសពីនេះ គោលការណ៍និងស្តង់ដារសិទ្ធិមនុស្សត្រូវតែជាចំណុចស្នូលនៃយន្តការមូលនិធិដោះស្រាយការបាត់បង់និងការខូចខាត និងប្រតិបត្តិការនៃនានាមូលនិធិនេះ។

ជាងនេះទៅទៀត ការបាត់បង់និងការខូចខាតដែលមិនទាក់ទងនឹងសេដ្ឋកិច្ចដល់ជនជាតិដើមភាគតិចក៏ត្រូវតែជាធាតុផ្សំនៃមូលនិធិដោះស្រាយការបាត់បង់និងការខូចខាតហើយគួរតែត្រូវបានកំណត់ដោយជនជាតិដើមភាគតិចខ្លួនឯង។

## ការកសាងសមត្ថភាពជនជាតិដើមភាគតិច តួអង្គមិនមែនជនជាតិដើមភាគតិច និងអង្គភាពរដ្ឋ

ការកសាងសមត្ថភាពរបស់ជនជាតិដើមភាគតិចពិតជាមានសារសំខាន់ណាស់ ជាពិសេសស្ត្រីជនជាតិដើមភាគតិច យុវជន និងជនមានពិការភាព ដើម្បីអនុញ្ញាតឱ្យមានការចូលរួមរបស់យើងនៅក្នុងដំណើរការ UNCBD និង UNFCCC។ វាក៏ចាំបាច់ផងដែរក្នុងការបង្កើនសមត្ថភាពរបស់ភាគីនិងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការចូលរួមប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិច និងដើម្បីទទួលបាននូវគោលការណ៍ FPIC ពីសហគមន៍ពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពអាកាសធាតុនិងជីវចម្រុះទាំងអស់។

## ការកៀរគរធនធាន និងហិរញ្ញវត្ថុ

ដីធ្លី ដែនដី ទឹក និងធនធានរបស់ជនជាតិដើមភាគតិចជាសម្បត្តិមួយផ្នែកធំនៃជីវចម្រុះដែលនៅសេសសល់របស់ពិភពលោក ហើយរួមចំណែកយ៉ាងធំធេងចំពោះគោលដៅរបស់ UNCBD និងUNFCCC។ ទោះបីជាមានការរួមចំណែកតិចតួចបំផុតដល់ការឡើងកំដៅផែនដី និងការបាត់បង់ជីវចម្រុះក៏ដោយ ក៏យើងជាអ្នករងផលប៉ះពាល់ខ្លាំងបំផុត និងមិនត្រូវបានផាត់ចេញពីធនធាននានាដែលត្រូវការដើម្បីដោះស្រាយវិបត្តិអាកាសធាតុនិងជីវចម្រុះ។

វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សត្រូវតែណែនាំការវិនិយោគនិងការកៀរគរហិរញ្ញវត្ថុពាក់ព័ន្ធនឹងដីធ្លី ដែនដី និងទឹករបស់ជនជាតិដើមភាគតិចដោយគោរពយ៉ាងពេញលេញទៅតាម UNDRIP ដោយធានានូវភាពជាម្ចាស់ ការដឹកនាំ ស្វ័យសម្រេចនិងស្វ័យគ្រប់គ្រង។

យន្តការហិរញ្ញវត្ថុក្រោមមូលនិធិក្របខណ្ឌជីវចម្រុះសកល( GBFF )មូលនិធិអាកាសធាតុបៃតង( GCF) និងមូលនិធិដោះស្រាយការបាត់បង់និងការខូចខាតក្នុងចំណោមនោះត្រូវតែមានសម្ភារៈបរិក្ខារដែលមានកម្មវិធីការងារពិសេសសម្រាប់ជនជាតិដើមភាគតិចរួមទាំងស្ត្រីជនជាតិដើមភាគតិច យុវជន និងជនមានពិការភាព។ យើងទាមទារនិងអំពាវនាវឱ្យប្រទេសនានា ជាពិសេសប្រទេសអភិវឌ្ឍន៍ត្រូវផ្តល់ហិរញ្ញវត្ថុដែលអាចងាយស្រួលប្រើប្រាស់ ប្រកបដោយមហិច្ឆតា និងអាចជឿទុកចិត្តបានពីប្រភពសាធារណៈដោយផ្តល់ផ្ទាល់ទៅដល់ជនជាតិដើមភាគតិច។ ហិរញ្ញប្បទានអាកាសធាតុនិងជីវចម្រុះមិនត្រូវកៀរគរក្នុងទម្រង់ជាកម្ចី ឬបំណុលទេ ប៉ុន្តែជាផ្នែកនៃគណនេយ្យភាពសង្គម-បរិស្ថាន និងទំនួលខុសត្រូវប្រវត្តិសាស្ត្រ។


Mr. Lakpa Nuri Sherpa (nuri@aippnet.org)
Ms. Pirawan Wongnithisathaporn (pirawan@aippnet.org)
Mr. Prem Singh Tharu (prem@aippnet.org)